# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ផសស ពិតនៅ US កើន ១,៩% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី១ ២០០៧ ធៀបនឹងកំណើន ៣,១% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ២០០៦ ។ នេះបណ្តាលមកពីកំណើនការនាំចូល ការធ្លាក់ចុះការនាំចេញ ការថយចុះចំណាយរដ្ឋាភិបាលសហព័ន្ធ និងការធ្លាក់ល្បឿនកំណើនចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ។ នៅត្រីមាសទី១ ២០០៧ ផសស ពិតនៅតំបន់អឺរ៉ូ មានកំណើន ៣,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និង ០,៦% ធៀបនឹងត្រីមាសមុន ។ ផសស ពិតនៅជប៉ុនកើន ២,២% ធៀបនឹងឆ្នាំមុន និងកើន ០,៦% ធៀបនឹងត្រីមាសមុន ។

នៅត្រីមាសទី១ ២០០៧ ចិន មានកំណើនសេដ្ឋកិច្ច ១១,១% ធៀបនឹងកាលពីមួយឆ្នាំមុន ។ កំណើននេះ នាំមុខដោយឧស្សាហកម្មដែលមានកំណើន ១៣,២% ធៀបនឹង ៩,៩% ក្នុងវិស័យសេវាកម្ម និង ៤,៤% ក្នុងវិស័យកសិកម្ម ។ វិនិយោគ និងពាណិជ្ជកម្ម នៅតែជាកំលាំងជំរុញចំបងដល់កំណើនសេដ្ឋកិច្ចនេះ ។ នៅត្រីមាសទី១ ផសស ពិតនៅកូរ៉េខាងត្បូង កើន ៤,០% ធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ០,៩% ធៀបនឹងត្រីមាសមុន ។ នៅត្រីមាសដដែល ផសស ពិត នៅតៃវ៉ាន់ និងហុងកុង កើន ៤,១% និង ៥,៦% ធៀបនឹងកាលពីមួយឆ្នាំមុន ។

សេដ្ឋកិច្ចនៅម៉ាឡេស៊ី កើន ៥,៣% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី១ ២០០៧ ។ កំនើនក្នុងត្រីមាសនេះ មានមូលដ្ឋានទូលាយដោយស្ទើរគ្រប់វិស័យចំបងៗសុទ្ធតែមានកំនើនលើកលែងតែការជីកយករ៉ែ ។ វិស័យសេវាកម្ម និងការរីកលូតលាស់កាន់តែលឿនក្នុងផ្នែកសំណង់ជាកត្តាគន្លឹះ ជំរុញឱ្យមានកំនើនសេដ្ឋកិច្ច ។ នៅត្រីមាសទី១ ២០០៧ ផសស ពិតនៅសិង្ហបុរី កើន ៦,០% ធៀបនឹងកាលពីមួយឆ្នាំមុន ។ ឧស្សាហកម្មផលិត និងសំណង់ កើន ៦,១% និង ៧,០% រីឯសេវាកម្ម កើន ៦,១% ។ ផសស ពិត នៅថៃ មានកំនើន ៤,៣% ។ វិស័យកសិកម្ម មានកំណើន ៤,៣% ធៀបនឹងកំណើន ១,៩% នៅត្រីមាសមុន ដោយសារផលដំណាំ និងផលនេសាទបានកើនឡើង ។ វិស័យមិនមែនកសិកម្ម ក៏កើន ៤,៣% ដែរ ធៀបនឹងកំណើន ៤,៦% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ២០០៦ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី១ ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅ US កើនតាមអត្រាប្រចាំឆ្នាំ ២,៤% ធៀបនឹងកំណើន ១,៩% នៅត្រីមាសមុន ។ រឿងនេះ បណ្តាលមកពីកំណើនថ្លៃម្ហូបអាហារ ថ្នាំពេទ្យ ផ្ទះស្នាក់នៅ និងថាមពល ។ នៅតំបន់អឺរ៉ូវិញ មានអតិផរណា ១,៩% ធៀបនឹងអតិផរណា ១,៨% នៅត្រីមាសមុន ។ កំនើននេះ ជំរុញដោយការឡើងថ្លៃធាតុចូល និងថ្លៃថាមពល ព្រមទាំងការតំលើងអាករលើតំលៃបន្ថែមនៅអាល្លឺម៉ង់នាពេលថ្មីៗនេះ ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់ ធ្លាក់ចុះ ០,១% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី១ ដោយសារជាសំខាន់ការចុះថ្លៃទូរគមនាគមន៍ ។ ប៉ុន្តែ អត្រាប្រែប្រួលនេះវាតិចតួចសឹងស្មើ ០% បើគេមិនរាប់បញ្ចូលនូវផលិតផលប្រេងកាត និងកត្តាពិសេសៗផ្សេងទៀត ។

នៅទីផ្សារប្តូរប្រាក់អន្តរជាតិ ដុល្លារUSប្រែប្រួលចំរុះ ទល់នឹងរូបិយវត្ថុដទៃទៀត ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១១៩,៤យ៉េន/ដុល្លារUS ធៀបនឹង ១១៧,៨យ៉េន/ដុល្លារUSនៅត្រីមាសមុន ។ ការឡើងថ្លៃដុល្លារUS នេះ វាទាក់ទងនឹងការរំពឹងទុករបស់ទីផ្សារអំពីគោលនយោបាយហិរញ្ញវត្ថុនៅជប៉ុន ។ ទល់នឹងប្រាក់អឺរ៉ូ និងប្រាក់យ៉ុនចិន ដុល្លារUS ប្តូរបាន ០,៧៦អឺរ៉ូ/ដុល្លារUS និង ៧,៧៦យ៉ុន/ដុល្លារUS គឺធ្លាក់ថ្លៃ បើធៀបនឹងអត្រា ០,៧៨អឺរ៉ូ/ដុល្លារUS និង ៧,៨៦យ៉ុន/ដុល្លារUSនៅត្រីមាសទី៤ ២០០៦ ។ ការធ្លាក់ថ្លៃដុល្លារUS មួយភាគធំបណ្តាលមកពីប្រតិកម្មនៃទីផ្សារចំពោះការថយចុះកំណើនសេដ្ឋកិច្ចនៅUS នៅពេលដែលប្រទេសមានសេដ្ឋកិច្ចធំៗឯទៀត និងប្រទេសមួយចំនួននៅអាស៊ាន កំពុងបន្តមានកំណើនសេដ្ឋកិច្ចខ្លាំងក្លា ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ២០០៧ ពោត ប្រេងឆា សណ្តែកសៀង អង្ករ និងសាំង ឡើងថ្លៃ រីឯប្រេងឆៅ និងម៉ាស៊ូត ធ្លាក់ថ្លៃ ។ ប្រេងឆាលក់បាន ៥៥២,០៦ ដុល្លារ/តោន ធៀបនឹង ៤៩៤,៩២ដុល្លារ/តោន នៅត្រីមាសទី៤ ២០០៦ ។ ពោត និងសណ្តែកសៀង លក់ថ្លៃ ១៥៤,៣៣ដុល្លារ/តោន និង ២៥៥,៣៣ ដុល្លារ/តោន ។ អង្ករ Thai 100%B លេខ២ នៅទីផ្សារបាងកក លក់ថ្លៃ ២៩៤,១៧ដុល្លារ/តោន ធៀបនឹង ២៧៩,១០ដុល្លារ/តោននៅត្រីមាសទី៤ ។ ថ្លៃសាំងនៅត្រីមាសទី១ ២០០៧ កើន ១,៧% ធៀបនឹងត្រីមាសមុន ដល់ ៧១,៧១សេន/លីត្រ រីឯថ្លៃប្រេងឆៅ និងម៉ាស៊ូតធ្លាក់ចុះ ៣,៩% និង ១,១% ។ ប្រេងឆៅ លក់ថ្លៃ ៥៤,២១ដុល្លារ/ធុង និងម៉ាស៊ូត ៤៥,៦១ដុល្លារ/ធុង ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភឹម រុនស៊ីណារិទ្ធិ*

**តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)**

| | 2001 | 2002 | 2003 | 2004 | 2005 | 2006* | | | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 8.0 | 6.5 | 8.5 | 10.0 | 13.5 | 10.8 | -1.6 | - | - | - |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 5.6 | 5.4 | 5.2 | 5.5 | 6.1 | - |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7.0 | 5.2 | 5.9 | 5.9 | 5.8 | 5.7 | 5.3 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 5.7 | 7.7 | 8.0 | 7.1 | 7.0 | 6.0 |
| ថៃ | 1.9 | 6.1 | 6.9 | 6.0 | 4.5 | 4.8 | 4.9 | 4.7 | 4.2 | 4.3 |
| វៀតណាម | 6.0 | 6.7 | 7.0 | 7.5 | 8.4 | 8.1 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.6 | 10.5 | 11.3 | 10.4 | 10.7 | 11.1 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 6.5 | 6.6 | 5.2 | 6.8 | 7.0 | 5.6 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3.0 | 4.7 | 4.7 | 5.0 | 5.3 | 4.8 | 5.0 | 4.0 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 4.1 | 4.6 | 4.6 | 5.0 | 4.0 | 4.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.5 | 2.7 | 2.4 | 2.6 | 3.3 | 3.0 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 2.5 | 2.1 | 2.2 | 2.7 | 2.3 | 2.2 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 3.7 | 3.3 | 3.5 | 3.3 | 3.1 | 1.9 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## តារាង ២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 5.8 | 4.7 | 4.5 | 4.9 | 3.4 | 3.0 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 10.5 | 13.4 | 15.5 | 14.9 | 6.1 | 6.4 |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 3.1 | 3.7 | 4.1 | 3.6 | 3.1 | 2.6 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.5 | 1.0 | 1.2 | 0.7 | 0.6 | 0.5 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 4.5 | 4.7 | 6.0 | 3.6 | 3.3 | 2.4 |
| វៀតណាម | -0.4 | 3.8 | 3.1 | 7.8 | 8.2 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 1.8 | 1.5 | 1.4 | 1.4 | 1.8 | 2.6 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 1.1 | 2.2 | 2.1 | 2.3 | 2.2 | 1.7 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 2.8 | 2.4 | 2.3 | 2.5 | 2.4 | 2.0 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 2.3 | 0.6 | 1.5 | -0.3 | -0.1 | 1.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | 0.0 | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.2 | 2.1 | 2.3 | 2.1 | 1.8 | 1.9 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.3 | 0.5 | 0.7 | 0.6 | 0.3 | -0.1 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.4 | 3.2 | 4.0 | 3.3 | 1.9 | 2.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

## តារាង ៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3916.3 | 3912.1 | 3973 | 4016.3 | 4092.5 | 4103.2 | 4095.3 | 4125.0 | 4111.3 | 4046.7 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9311 | 8577 | 8938 | 9705 | 9134 | 9115 | 9122 | 9125 | 9107 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.79 | 3.67 | 3.65 | 3.67 | 3.62 | 3.50 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.66 | 1.59 | 1.59 | 1.58 | 1.56 | 1.53 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 40.2 | 37.9 | 38.1 | 37.7 | 36.5 | 33.9 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,859 | 15,994 | 15,964 | 16,015 | 16,077 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.19 | 7.97 | 8.01 | 7.97 | 7.86 | 7.76 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.78 | 7.77 | 7.76 | 7.78 | 7.78 | 7.81 |
| កូរ៉េខាងត្បូង (វ៉ុន) | 1291 | 1251 | 1192 | 1145 | 1024 | 955 | 949 | 955 | 938 | 939 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 32.1 | 32.5 | 32.2 | 32.8 | 32.8 | 32.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.80 | 0.80 | 0.80 | 0.78 | 0.78 | 0.76 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 110.2 | 116.4 | 114.5 | 116.3 | 117.8 | 119.4 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

## តារាង ៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 89.19 | 111.04 | 99.95 | 108.67 | 140.18 | 154.33 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 381.32 | 433.85 | 397.87 | 446.85 | 494.92 | 552.06 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 262.88 | 282.00 | 283.86 | 289.91 | 279.10 | 294.17 |
| សណ្តែកសៀង (US No. 1) – US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 224.25 | 213.88 | 207.02 | 207.38 | 230.17 | 255.33 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 50.14 | 61.58 | 65.03 | 67.00 | 56.39 | 54.21 |
| សាំង – US Gulf coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 42.19 | 47.70 | 55.89 | 52.70 | 41.02 | 41.71 |
| ម៉ាស៊ូត (ស្តង់ដ័រតិច លេខ២) – US Gulf coast (សេន/លីត្រ) | 18.72 | 17.85 | 21.63 | 29.48 | 44.35 | 51.35 | 55.89 | 55.66 | 46.11 | 45.61 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី១ ២០០៧ ការធ្លាក់ចុះគំរោងវិនិយោគឯកជនបានអនុម័ត បានកាត់បន្ថយកំណើនសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេស ដោយសារតែវិស័យនេះជាកត្តាជំរុញយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ទោះយ៉ាងនេះក្តី គំរោងសាងសង់បានអនុម័ត និងចំនួនភ្ញៀវទេសចរណ៍មកដល់កម្ពុជា បានកើនឡើងធៀបនឹងត្រីមាសមុន ប៉ុន្តែឱនភាពពាណិជ្ជកម្ម ក៏កើនឡើងយ៉ាងខ្លាំងដែរ ។

គំរោងវិនិយោគសរុបបានអនុម័ត មាន ៤៩៧,៥លានដុល្លារ រឺថយចុះ ៤៩% ធៀបនឹងត្រីមាសមុន ។ គំរោងវិនិយោគក្នុងវិស័យកសិកម្មធ្លាក់ចុះ ៨៨% មកត្រឹម ១៩,១លានដុល្លារ និងក្នុងវិស័យសេវាកម្មធ្លាក់ចុះ ៥៥% មកត្រឹម ៣៣៥,៧លានដុល្លារ រីឯគំរោងសំរាប់វិស័យឧស្សាហកម្មវិញ កើន ៨៦% ដល់ ១៤២,៧លានដុល្លារ ។ គំរោងវិនិយោគសំរាប់វិស័យកសិកម្ម គឺសុទ្ធតែជាគំរោងកសិ-ឧស្សាហកម្មទាំងអស់ក្នុងអំឡុងពេលនេះ ។ ចំពោះគំរោងវិនិយោគក្នុងវិស័យឧស្សាហកម្ម គំរោងសំរាប់វិស័យកាត់ដេរមាន ២៦% រឺ ៣៦,៦លានដុល្លារ ដោយកើន ៤១% ធៀបនឹងត្រីមាសមុន ។ គំរោងក្នុងវិស័យទេសចរណ៍ ជាកត្តាជំរុញសំខាន់មួយនៃវិនិយោគក្នុងវិស័យសេវាកម្មដែលមានតំលៃ ១៤០,៣លានដុល្លារ រឺធ្លាក់ចុះ ៥៦% ។ នៅត្រីមាសទី១ ២០០៧ មាន ២៥គំរោង ត្រូវបានអនុម័ត ក្នុងនោះមាន ២ ជាគំរោងផ្នែកកសិកម្មដែលត្រូវការកម្មករថ្មីៗចំនួន ១៩៦៥នាក់ ។ ក្នុងនោះ វិស័យឧស្សាហកម្មមាន ១៧គំរោង និងត្រូវការកម្មករចំនួន ២៩៧៨៩នាក់ រីឯវិស័យសេវាកម្មវិញមាន ៦គំរោង និងត្រូវការកម្មករចំនួន ៣៥៧៥នាក់ ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ គំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់បានអនុម័ត បានកើនឡើងទ្វេដង ។ គំរោងក្នុងវិស័យសេវាកម្ម កើន ១ ជា ៦ នៅត្រីមាសទី១ ២០០៦ ហើយក្នុងវិស័យឧស្សាហកម្ម កើន ១ជា៤ រីឯគំរោងក្នុងវិស័យកសិកម្មធ្លាក់ចុះ ៨៥% ។ ឧត្តមភាពប្រៀបធៀបសំរាប់ការវិនិយោគនៅកម្ពុជា គឺថ្លៃដើមផលិតកម្មទាប និងមិនមានការរឹតបណ្តឹងកូតាចំពោះការនាំចេញទៅអាមេរិកនិងតំបន់អឺរ៉ុ ។ បច្ចុប្បន្នរោងចក្រកាត់ដេរភាគច្រើនមានម្ចាស់ជាជនបរទេស ហើយនៅត្រីមាសទី១ ២០០៧ មាន ៥៧% នៃគំរោងគិតជាទ្រព្យសកម្មជាប់លាប់ ជាសំនើរបស់វិនិយោគិនបរទេស ។

នៅត្រីមាសទី១ ២០០៧ គំរោងសាងសង់បានអនុម័តនៅទីក្រុងភ្នំពេញមាន ៩០,៤លានដុល្លារ រឺកើន ១៦% ធៀបនឹងត្រីមាសមុន ។ គំរោងផ្ទះល្វែងកើន ១០% ដល់ ៥៩,៩លានដុល្លារ និងគំរោងផ្ទះនិងភូមិគ្រឹះ កើន ១២% ដល់ ១០,៩លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៦ គំរោងសាងសង់សរុបបានអនុម័ត កើន ៣៤% ក្នុងនោះ គំរោងផ្ទះល្វែង កើន ៥០% និងផ្ទះនិងភូមិគ្រឹះ កើន ៧,៩% ។ គំរោងសាងសង់ពិតប្រាកដ នៅទីក្រុងភ្នំពេញនៅឆ្នាំ២០០៦ មាន ៣០៦,៦លានដុល្លារ (៦៨៥ គំរោង) ដែលក្នុងនោះមាន ៨៦% បានស្នើសុំការអនុញ្ញាតឱ្យសាងសង់ពីសាលាក្រុងភ្នំពេញ និងចំនួននៅសល់បានសាងសង់ដោយមិនបានសុំការអនុញ្ញាតជាមុនទេ ។

ឱនភាពពាណិជ្ជកម្មនៅកម្ពុជា កើន ១៨% ធៀបនឹងត្រីមាសមុន ដល់ ៨៣,១លានដុល្លារ ។ ការនាំចេញធ្លាក់ចុះអស់ ២ត្រីមាសបន្តបន្ទាប់គ្នា បន្ទាប់ពីកំណើននៅត្រីមាសទី៣ ២០០៦ ហើយការនាំចូលក៏ធ្លាក់ចុះដែរ បន្ទាប់ពីមានកំណើនអស់ជាច្រើនត្រីមាសកន្លងមក ។ នៅត្រីមាសទី១ ២០០៧ ការនាំចេញសរុបធ្លាក់ចុះ ៣,៩% មកត្រឹម ៧០៧,៨លានដុល្លារ ។ ការនាំចេញក្នុងវិស័យកាត់ដេរ ដូចជា សំលៀកបំពាក់ ស្បែកជើង និងផលិតផលវាយនភ័ណ្ឌផ្សេងទៀត បានធ្លាក់ចុះ ៥,៤% មកត្រឹម ៦៧៧,៥លានដុល្លារ ។ ទាំងការនាំចេញឈើ និងត្រី កើន ៣០% ដល់ ២,១លានដុល្លារ និង ០,៧លានដុល្លារ រីឯការនាំចេញកៅស៊ូ ថយចុះ ២០% មកត្រឹម ៨,៤លានដុល្លារ ។ ការនាំចេញសរុបរបស់កម្ពុជា កើន ១៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ដោយការនាំចេញសំលៀកបំពាក់ កើន ២០% រីឯការនាំចេញផលិតផលកសិកម្មធ្លាក់ចុះ ១៣% ។

ការនាំចូលរបស់កម្ពុជាធ្លាក់ចុះ ២,០% ធៀបនឹងត្រីមាសមុន មកត្រឹម ៧៩០,៩លានដុល្លារ បន្ទាប់ពីកំណើន ៣ត្រីមាសមក ។ ការនាំចូលម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ធ្លាក់ចុះ ១,៦% មកត្រឹម ៤២,៣លានដុល្លារ រីឯសំភារៈសំណង់កើន ២៤% ដល់ ៤៤,១លានដុល្លារ ។ ការនាំចូលសាំង កើន ៤,៤% ដល់ ១៥,៧លានដុល្លារ និងការនាំចូលម៉ាស៊ូត កើន ១៨% ដល់ ៣១,៩លានដុល្លារ ។ បើគិតពីបរិមាណ ការនាំចូលសាំង កើន ២០% ដល់ ៥០.៨៥០តោន និងការនាំចូលម៉ាស៊ូត កើន ២១% ដល់ ១១៥.៧៤០តោន ។ ការនាំចូលសរុប កើន ១៥% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ។

នៅត្រីមាសទី១ ២០០៧ ភ្ញៀវបរទេសមកដល់កម្ពុជាសរុបមានចំនួន ៥៥០.៨១៣នាក់ រឺកើន ៦,៧% ធៀបនឹងត្រីមាសមុន និងកើន ២០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ។ ចំនួនភ្ញៀវមកដល់តាមផ្លូវអាកាស កើន ៣៦% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដល់ ៣៧៣.៥៩៤នាក់ ។ អាកាសយានដ្ឋានអន្តរជាតិសៀមរាបទទួលបាន ៤៣% នៃភ្ញៀវមកដល់តាមផ្លូវអាកាស និង ៥៩% នៃភ្ញៀវទៅសៀមរាប ។ ភ្ញៀវមកដល់តាមផ្លូវគោកមាន ១៦២.៥៤៧នាក់ រឺធ្លាក់ចុះ ៣,៨% ធៀបនឹងត្រីមាសដូចគ្នាមួយឆ្នាំមុន រីឯភ្ញៀវមកដល់តាមផ្លូវទឹក កើន ១៣% ដល់ ១៤.៦៧២នាក់ ។ ភ្ញៀវមកលំហែកាយមាន ៩០% នៃភ្ញៀវសរុប ។ ភ្ញៀវកូរ៉េមានច្រើនជាងគេ ដល់ ១១៨.៥៩៧នាក់ បន្ទាប់មកគឺភ្ញៀវជប៉ុន អាមេរិក និងតៃវ៉ាន់ ។

## ហិរញ្ញវត្ថុសាធារណៈ

តាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដំណើរការរៀបចំរបាយការណ៍ថវិការដ្ឋត្រូវបានផ្លាស់ប្តូរនៅខែមករា ២០០៧ ។ បច្ចុប្បន្នសមាសភាពចំនាយចរន្តត្រូវបានរាយការណ៍ជាបៀវត្សរ៍ ការទិញរបស់រដ្ឋាភិបាល ឧបត្ថម្ភធននិងជំនួយសង្គម និងសេវាកម្មផ្សេងៗទៀត ជំនួសឱ្យការចំណាយសរុបដោយក្រសួងនីមួយៗ ដូចបានរាយការណ៍ពីមុនៗមក ។ ចំពោះការបង្ហាញពីចំណូលចរន្តនៅក្នុងរបាយការណ៍របស់ MEF មានការផ្លាស់ប្តូរបន្តិចបន្តួច ។ នៅខែមករា (ទិន្នន័យដែលមានសំរាប់ត្រីមាសទី១ ២០០៧) ថវិការបស់រដ្ឋាភិបាលមានអតិរេក ៦៥,៤ពាន់លានរៀល ធៀបនឹងឱនភាព ១២៨,៧ពាន់លានរៀលនៅអំឡុងពេលដូចគ្នាឆ្នាំ២០០៦ ។ នៅខែមករា ចំណូលសរុបមានចំនួន ២៥៨,០ពាន់លានរៀល ក្នុងនោះចំណូលបានពីពន្ធមាន ៨៦% រឺ ២២២,៥ពាន់លានរៀល ។ ពន្ធក្នុងស្រុកមាន ៦៨% នៃចំណូលពន្ធសរុប ហើយវាមានធាតុផ្សំដូចជាពន្ធលើប្រាក់ចំណេញ អាករលើផលរបរ អាករពិសេស និងពន្ធផ្សេងទៀត ។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិ រួមមានពន្ធលើការនាំចូល និងការនាំចេញមាន ៧២,២ពាន់លានរៀល ។ ចំណូលមិនមែនពន្ធមាន ៣៥,៥ពាន់លានរៀល រឺ ១៤% នៃចំណូលសរុប ។ ចំណូលពីអចលនទ្រព្យមាន ៨,២% នៃចំណូលមិនមែនពន្ធសរុប និងការលក់ទំនិញនិងសេវាកម្មរបស់រដ្ឋាភិបាលមាន ៨៥% ។ ចំណូលមូលធន គឺសូន្យ នៅខែមករា ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅខែមករា ចំនាយថវិកា មាន ១០១,៧ពាន់លានរៀល ។ ចំណាយចរន្ត មាន ២៥,៨ពាន់លានរៀល ដែលប្រាក់បៀវត្សរ៍មន្ត្រីរដ្ឋាភិបាលមាន ៥៣% ការផ្គត់ផ្គង់និងជំនួយសង្គមមាន ១៥% និងបន្ទុកចំណាយហិរញ្ញវត្ថុមាន ៦,២% ។ នៅអំឡុងពេលដូចគ្នា ចំណាយមូលធនមាន ៧៦,០ពាន់លានរៀល ភាគច្រើនជាមូលនិធិផ្ដល់ដោយខាងក្រៅ និងមានតែ ១,៨%ប៉ុណ្ណោះ ដែលផ្ដល់ដោយរដ្ឋាភិបាល ។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី១ ២០០៧ ថ្លៃទំនិញ និងសេវាទូទៅនៅភ្នំពេញធ្លាក់ចុះ ០,៦% ធៀបនឹងត្រីមាសមុន ។ ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ធ្លាក់ចុះ ១,១% ថ្លៃម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ធ្លាក់ចុះ ២,០% និងថ្លៃសំលៀកបំពាក់និងស្បែកជើងធ្លាក់ចុះ ០,៥% រីឯថ្លៃផ្ទះស្នាក់នៅនិងថ្លៃទឹកភ្លើងកើន ០,២% ថ្លៃថែទាំសុខភាព កើន ០,៣% និងថ្លៃផលិតផលថែទាំកាយ កើន ០,៦% ។ នៅរដូវប្រាំង ក្នុងត្រីមាសទី១ ឆ្នាំ២០០៧ ថ្លៃទំនិញ និងសេវាទូទៅ កើន ២,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ដែលក្នុងនោះថ្លៃថែទាំសុខភាពកើន ២,៤% ថ្លៃម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ កើន ៣,០% ថ្លៃសំលៀកបំពាក់និងស្បែកជើង កើន ៣,៥% និងថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ៥,២% ។

បន្ទាប់ពីការធ្លាក់ថ្លៃនៅត្រីមាសទី៣ និងការឡើងថ្លៃនៅត្រីមាសទី៤ ២០០៦ ប្រាក់រៀលបានឡើងថ្លៃ នៅត្រីមាសទី១ ២០០៧ ដោយមានអត្រាប្ដូរប្រាក់ ៤០៦៣រៀល/ដុល្លារUS រីឡើងថ្លៃ ១,៦% ធៀបនឹងត្រីមាសមុន ។ ទល់នឹងប្រាក់បាតថៃ ប្រាក់រៀលធ្លាក់ថ្លៃ ០,៨% ដោយប្ដូរបាន ១១៣,៧ រៀល/បាត ហើយទល់នឹងប្រាក់ដុងវៀតណាម វាឡើងថ្លៃ ១,១% ដល់ ២៤,៦រៀល/១០០ដុង ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប្រាក់រៀលឡើងថ្លៃ ០,៨% ទល់នឹងដុល្លារUS និង ៣,២% ទល់នឹងប្រាក់ដុងវៀតណាម ហើយវាធ្លាក់ថ្លៃ ១០,០% ទល់នឹងប្រាក់បាតថៃ ។

## ការវិវត្តន៍រូបិយវត្ថុ

ទ្រព្យសកម្មក្នុងស្រុកសុទ្ធ រួមមាន ឥណទានក្នុងស្រុក និង "បំណុលផ្សេងៗ" ។ "បំណុលផ្សេងៗ" ជានិច្ចជាកាល មានសមតុល្យអវិជ្ជមានដោយសារវាជាបំណុលរបស់ប្រព័ន្ធធនាគារ ហើយសមាសភាពនេះជារឿយៗ បណ្ដាលឱ្យទ្រព្យសកម្មក្នុងស្រុកសុទ្ធ មានភាពអវិជ្ជមានផងដែរ ។ នៅត្រីមាសទី១ ២០០៧ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ មាន-២៦៣,១ពាន់លានរៀល ដែលជាចំនួនអវិជ្ជមាន ប៉ុន្តែកើនឡើង ៦៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ក្នុងនោះ "បំណុលផ្សេងៗ" កើន ១៦% ដល់ ៣១៥៥,២ពាន់លានរៀល ។ រីឯឥណទានក្នុងស្រុក ក៏កើនដែរបាន ៤៣% ដល់ ២៨៩២,១ ពាន់លានរៀល ដែលក្នុងនោះឥណទានរដ្ឋាភិបាល កើន ៧,៤% ដល់ ២៩៨,០ ពាន់លានរៀល និងឥណទានឯកជន កើន ៤៦% ដល់ ៤០៦៧,៧ពាន់លានរៀល រីឯបញ្ញើរដ្ឋាភិបាលកើន ៤៣% ដល់ ១៤៧៣,៥ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធកើន ២៦% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៦ ដល់ ៨០៥៦,៣ពាន់លានរៀល ។ ទ្រព្យសកម្មសុទ្ធរបស់ប្រព័ន្ធធនាគារបានផ្ដល់នូវរូបិយវត្ថុទូទៅ (M2) ចំនួន ៧៧៩៣,២ពាន់លានរៀល រីកើន ៣៦% ធៀបនឹងត្រីមាសទី១ ២០០៦ ។ រូបិយវត្ថុទូទៅ (M2) រួមមាន បំណុលរបស់ប្រព័ន្ធធនាគារដែលជារូបិយវត្ថុនៅក្រៅធនាគារ បានកើនឡើង ២៤% ដល់ ១៧៣៣,៦ពាន់លានរៀល បញ្ញើជាប្រាក់រៀលធ្លាក់ចុះ ៣,៩% មកត្រឹម ១៥៤,៨ពាន់លានរៀល និងប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើន ៤២% ដល់ ៥៩០៤,៧ពាន់លានរៀល ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅខែឧសភា ២០០៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះចំនួន ១០ក្រុម កើន ១៦% ដល់ ៨២៤០រៀល ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៦ (មើលតារាង) ។ ទោះយ៉ាងនេះក្តី ប្រាក់ចំនូលរបស់កម្មករសំនង់ គ្មានជំនាញ ធ្លាក់ចុះ ៥% និងរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះ ១% ។

ចំនួលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប កើន ៤៧% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ដល់ ១២.៨០០រៀល ។ កំណើននេះដោយសារតែការធ្វើការច្រើនម៉ោង (១១ម៉ោងក្នុងមួយថ្ងៃ) និងមានតំរូវការខ្ពស់ ។ អ្នកឆ្លើយសំភាសន៏ ៦០% បានជួលផ្ទះ ១០% ស្នាក់នៅជាមួយបងប្អូន និងអ្នកផ្សេងទៀតមានផ្ទះនៅក្នុងទីក្រុង រីនៅជាយក្រុង ។ម្យ៉ាងទៀត អ្នករត់ម៉ូតូឌុប ៩៥% បាននិយាយថា គ្រួសាររបស់ពួកគេឥឡូវមានជីវភាពធូរធារ រីឯ ៥% ទៀតថាមិនមានភាពធូរធារអ្វីសោះ ចាប់តាំងពីពួកគេមកធ្វើការនៅទីក្រុង ។ អ្នករត់ម៉ូតូឌុប ៤៥% បានធ្វើការងារជាង៥ឆ្នាំហើយ ៣៧,៥% ធ្វើការបានពី ៣-៥ឆ្នាំ និង ១៧,៥% តិចជាង៣ឆ្នាំ ។ ពួកគេ ៩៥% បានរាយការណ៍ថា ប្រាក់ចំណូលរបស់ពួកគេមិនគ្រប់គ្រាន់សំរាប់បង្កើតមុខរបរថ្មីទេ ប្រសិនបើពួកគេចាកចេញពីការងារបច្ចុប្បន្ន ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ កើន ២១% ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន ។ កម្មករមានជំនាញ ៦៨% បានបង្ហាញថា គំរោងសាងសង់នៅទីក្រុងបានកើនឡើងយ៉ាងខ្លាំង ដូច្នេះមានការងារច្រើនជាងឆ្នាំមុន ។ កម្មករមានជំនាញចំណាយប្រហែល ៣៥០០រៀល សំរាប់អាហារប្រចាំថ្ងៃ និងប្រហែល ១៣០.០០០រៀលក្នុងមួយខែ ។ ពួកគេ ៩៥% មកពីជនបទ ហើយមាន ៤៥% នៅលីវ ។ ផ្ទុយទៅវិញ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៥% ធៀបនឹងខែឧសភា ២០០៦ ។ អ្នកឆ្លើយសំភាសន៏ ៧៧% បាននិយាយថា មូលហេតុដែលធ្វើឱ្យចំណូលពួកគេធ្លាក់ចុះ គឺដោយសារតែកំណើននៃចំនួនកម្មករ ។ ទោះយ៉ាងនេះក្តី កម្មករគ្មានជំនាញ ៣៨% យល់ឃើញថា គ្រួសាររបស់ពួកគេមានជីវភាពធូរធារ តាំងពីពួកគេមកធ្វើការនៅទីក្រុង ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយមាន ៥៥៣៣រៀល រីកើន ២៣% ធៀបនឹងអង្កេតមួយឆ្នាំមុន ហើយកើន ២២% ធៀបនឹងអង្កេតនៅ ៣ខែមុន ។ អ្នករើសអេតចាយ ៦០% បានរាយការណ៍ថា ថ្លៃអេតចាយកើនឡើងនៅរយៈ៣ខែដល់ខែឧសភា ។ ពួកគេ ៩៥% បាននិយាយថា បើតាមចំណូលនេះ ពួកគេមិនអាចសន្សំប្រាក់ ដើម្បីបង្កើតមុខរបរថ្មីបានទេ ។ អ្នករើសអេតចាយ ៤៣% បានខ្ចីប្រាក់ពីឈ្មួញកណ្ដាល រីអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗនៅពេលគ្រួសារពួកគេខ្វះខាតម្ហូបអាហារ រីមានជំងឺ ។

ចំណូលរបស់អ្នកធាក់ស៊ីក្លូ កើនឡើង ៨% ពី ៨៥៤៦រៀល នៅឆ្នាំមុន ដល់ ៩២៥០រៀល ។ អ្នកធាក់ស៊ីក្លូ បានចំនាយពេលច្រើនប្រហែល ១១ម៉ោង ក្នុងមួយថ្ងៃ ដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគេ ។ អ្នកផ្សេងទៀត មានម៉ូយប្រចាំ ដែលជានិច្ចជាកាលជាពាណិជ្ជករនៅក្នុងផ្សារ ។ ទោះយ៉ាងនេះក្តី

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

អ្នកធាក់ស៊ីក្លូបានត្អូញត្អែរថា ពួកគេមិនអាចសន្សំប្រាក់បានគ្រប់គ្រាន់ ដើម្បីបង្កើតមុខរបរថ្មីផ្សេងទៀតទេ ។ ៥៥% ទៀតនិយាយថា ជីវភាពគ្រួសាររបស់ពួកគេនៅដដែល ១០%ទៀតថា មានភាពលំបាកជាងមុន និង ៣៥% ទៀតថា មានភាពល្អប្រសើរនៅពេលប្រកបរបរនេះ ។

ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាចមាន ៨៩៥០រៀល រឺកើន ៣៨% ធៀបនឹងខែឧសភា ២០០៦ ។ អ្នកលក់បន្លែតូចតាចចំនួន ១៨% នៅលីវ ហើយពួកគេដើរតួយ៉ាងសំខាន់ក្នុងការជួយផ្គត់ផ្គង់គ្រួសារ ។ ពួកគេភាគច្រើនបានរាយការណ៍ថា គ្រួសារពួកគេបានធូរធារតាំងពីពួកគេចាប់ផ្តើមមុខរបរនេះ ។

ចំណូលរបស់កម្មករកាត់ដេរ កើន ៦% ធៀបនឹងមួយឆ្នាំមុន ដោយកើនពី ៧៨៦០រៀល ដល់ ៨៣៥០រៀល ។ ភាគច្រើននិយាយថា ពួកគេធ្វើការច្រើនជាង៤៨ម៉ោងក្នុងមួយសប្តាហ៍ ។ កម្មករកាត់ដេរ ៤៦% បានរាយការណ៍ថា អាចរកបានពី៥៦ដុល្លារ-៧០ដុល្លារ/ខែ និង ២៦% ទៀតថា អាចរកបានច្រើនជាង ៧០ដុល្លារ/ខែ ។ អង្កេតបានបង្ហាញថា កម្មករកាត់ដេរ ៣៥% បានធ្វើការដដែលអស់រយៈពេលប្រហែលជាង៥ឆ្នាំហើយ ៣៩% ធ្វើការបានពី២-៥ឆ្នាំ ១២% ធ្វើការបាន១-២ឆ្នាំ និង ១៤% ធ្វើការបាន១ឆ្នាំ ។ កម្មករ ១៣% បានរាយការណ៍ថា អាចសន្សំប្រាក់បានមួយចំនួនដើម្បីផ្តល់ទៅឱ្យគ្រួសារ រីឯកម្មករផ្សេងទៀតថា អាចផ្តល់ប្រាក់ទៅឱ្យគ្រួសារ បានត្រឹមតែមួយរយៈប៉ុណ្ណោះ ។

អង្កេតបានបង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកបំរើតាមភោជនីយដ្ឋាន ធ្លាក់ចុះ ១% ធៀបនឹងខែឧសភា ឆ្នាំ២០០៦ ។ ពួកគេប្រហែល ៥៧% បានផ្ញើប្រាក់ទៅផ្ទះដើម្បីជួយផ្គត់ផ្គង់គ្រួសារ ដូច្នេះគ្រួសារពួកគេភាគច្រើន មានជីវភាពធូរធារជាងមុន ។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែនៅនឹងដដែលគឺ ៤៥៣០រៀល ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៦ ។ អ្នកស៊ីឈ្នួលធ្វើស្រែ ៧០%និយាយថា ជីវភាពគ្រួសារពួកគេគឺនៅដដែល ។ ៦៥% ថា បានចំណាយភាគច្រើនលើម្ហូបអាហារ ហើយអ្នកផ្សេងទៀតថា គឺចំណាយលើការថែទាំសុខភាព ។ ម្យ៉ាងទៀត ៤៣% និយាយថា ពួកគេបានខ្ចីប្រាក់ពីម្ចាស់ដីស្រែដោយសងវិញតាមការលក់កំលាំងពលកម្មរបស់ពួកគេឱ្យម្ចាស់ដីស្រែទាំងនោះ ។

*រៀបរៀងដោយ*
*ប៊ុន ដូរីណា និង ផាន់ ដាលីស*

**តារាង ១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ១៩៩៩-២០០៧**

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 63.9 | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 26.8 | 126.5 | 216.9 | 0.0 | 154.6 | 19.1 |
| ឧស្សាហកម្ម | 162.6 | 109.4 | 105.2 | 67.7 | 137.2 | 189.2 | 912.6 | 40.1 | 76.9 | 171.7 | 76.6 | 142.7 |
| កាត់ដេរ | 67.7 | 81.5 | 26.5 | 27.2 | 68.1 | 133.9 | 152.0 | 30.5 | 9.6 | 23.2 | 26.1 | 36.6 |
| សេវាកម្ម | 222.6 | 150.1 | 118.4 | 145.3 | 168.4 | 92.0 | 155.5 | 60.7 | 2,043.2 | 94.5 | 740.7 | 335.7 |
| សណ្ឋាគារ និងទេសចរណ៍ | 171.8 | 79.8 | 73.8 | 47.1 | 124.1 | 55.9 | 102.6 | 0.0 | 26.2 | 3.5 | 315.3 | 140.3 |
| សរុប | 449.1 | 269.2 | 224.0 | 253.3 | 309.3 | 293.5 | 1094.9 | 227.3 | 2,337.0 | 266.2 | 971.9 | 497.5 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 90.7 | 928.1 | -88.6 | 265.1 | -48.8 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -47.6 | -40.0 | -16.8 | 13.1 | 22.1 | -5.1 | 273.0 | -52.2 | 2331.2 | -34.1 | 715.4 | 118.9 |

*Including expansion project approvals. Up to June 2006. Source: Cambodian Investment Board*

**តារាង ២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ១៩៩៩-២០០៧**

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 45.5 | 10.1 | 5.7 | 7.6 | 9.7 | 10.9 |
| ផ្ទះល្វែង | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 204.2 | 39.9 | 51.8 | 67.1 | 54.5 | 59.9 |
| ផ្សេងៗ | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 109.1 | 17.4 | 24.7 | 20.8 | 13.9 | 19.5 |
| សរុប | 326.9 | 205.4 | 196.3 | 219.9 | 198.9 | 263.5 | 358.8 | 67.4 | 82.2 | 95.5 | 78.2 | 90.4 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -6.2 | 22.2 | 16.1 | -18.1 | 15.6 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 18.7 | -37.2 | -4.4 | 12.0 | -9.5 | 32.5 | 36.2 | -36.5 | -21.2 | 24.8 | 8.9 | 34.2 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង ៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៩-២០០៧

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 941.1 | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 644.8 | 603.2 | 652.5 | 807.5 | 736.7 | 707.8 |
| រួមមាន: សំលៀកបំពាក់ | 554.0 | 962.1 | 1202.2 | 1355.8 | 1628.4 | 2027.0 | 601.0 | 568.5 | 632.4 | 782.0 | 716.0 | 677.5 |
| - ទៅសហរដ្ឋអាមេរិក | 486.0 | 714.1 | 840.9 | 943.4 | 1099.8 | 1270.9 | 408.1 | 402.5 | 438.6 | 522.8 | 483.2 | 499.1 |
| - ទៅសហភាពអឺរ៉ុប | - | 228.1 | 323.3 | 356.3 | 414.7 | 590.8 | 145.3 | 110.6 | 142.2 | 188.1 | 160.1 | 106.3 |
| - ប្រទេសផ្សេងទៀត | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 165.3 | 47.5 | 55.3 | 51.6 | 71.0 | 72.8 | 72.0 |
| កសិកម្ម | - | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 43.8 | 34.7 | 20.2 | 25.5 | 20.7 | 30.3 |
| - កៅស៊ូ | - | 29.6 | 25.9 | 29.7 | 35.1 | 38.3 | 13.4 | 7.8 | 9.8 | 13.6 | 10.2 | 8.4 |
| - ឈើ | - | 32.9 | 22.3 | 16.0 | 10.2 | 11.1 | 2.0 | 2.1 | 2.3 | 2.5 | 1.7 | 2.1 |
| - ត្រី | - | 5.4 | 6.0 | 4.3 | 2.8 | 10.6 | 6.6 | 1.9 | 1.0 | 1.6 | 1.4 | 0.7 |
| - ផ្សេងៗ | - | 26.2 | 11.8 | 47.4 | 31.6 | 21.3 | 21.9 | 22.9 | 7.0 | 7.7 | 7.5 | 19.0 |
| ការនាំចូលសរុប | 1237.4 | 1417.7 | 1501.4 | 1707.8 | 1824.9 | 2149.0 | 691.1 | 690.7 | 774.9 | 784.3 | 807.1 | 790.9 |
| រួមមាន: - សាំង | - | - | - | 25.9 | 33.2 | 30.2 | 10.7 | 10.9 | 12.4 | 13.1 | 13.2 | 15.7 |
| - ម៉ាស៊ូត | - | - | - | 100.8 | 109.6 | 109.4 | 21.1 | 32.5 | 32.2 | 30.1 | 27.2 | 31.9 |
| - សំភារៈសំណង់ | - | - | - | 12.9 | 80.8 | 95.3 | 26.2 | 37.0 | 39.1 | 42.5 | 35.8 | 44.1 |
| - ផ្សេងៗ | - | - | - | 1568.2 | 1601.3 | 1914.0 | 633.1 | 610.3 | 691.2 | 698.5 | 731.0 | 699.2 |
| ជញ្ជីងពាណិជ្ជកម្ម | -296.3 | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -46.3 | -87.5 | -122.4 | 23.2 | -70.4 | -83.1 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | -15.3 | -5.4 | 11.2 | 23.7 | -8.4 | -5.4 |
| ការនាំចេញសរុប | - | - | - | - | - | - | -11.7 | -6.4 | 8.2 | 23.7 | -8.8 | -3.9 |
| ការនាំចូលសរុប | - | - | - | - | - | - | 9.3 | -0.03 | 12.2 | -1.6 | 5.9 | -2.0 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 15.5 | 27.8 | 27.1 | 10.2 | 19.1 | 19.2 |
| ការនាំចេញសរុប | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 18.3 | 30.3 | 26.7 | 10.6 | 14.3 | 17.3 |
| ការនាំចូលសរុប | 11.3 | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 26.1 | 32.6 | 15.6 | 20.9 | 16.8 | 14.5 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF.*

## តារាង ៤. ចំនួនភ្ញៀវបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០៧

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ភ្ញៀវពាន់នាក់ | | | | | | |
| តាមផ្លូវអាកាស | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 856.5 | 275.4 | 204.4 | 224.2 | 325.0 | 373.6 |
| តាមផ្លូវគោក និងទឹក | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 565.1 | 181.9 | 153.6 | 146.4 | 191.0 | 177.2 |
| សរុប | 367.7 | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 1421.6 | 457.3 | 358.0 | 370.6 | 516.0 | 550.8 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | - | - | 9.9 | -21.7 | 4.1 | 39.2 | 6.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 34.7 | 20.2 | 21.2 | 14.7 | 24.1 | 20.4 |

*Source: Ministry of Tourism*

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៩-២០០៧ (ពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q2 | Q3 | Q4 | 2007 Q1* |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 920 | 1326 | 1528 | 1530 | 1744 | 1764 | 2126 | 2625 | 731.5 | 732.2 | 1199.2 | 258.0 |
| ចំណូលចរន្ត | - | - | - | 1521 | 1728 | 1733 | 2107 | 2474 | 726.9 | 716.8 | 844.4 | 258.0 |
| ចំណូលពន្ធ | 676 | 956 | 1096 | 1096 | 1227 | 1220 | 1577 | 1911 | 558.6 | 565.8 | 661.3 | 222.5 |
| ពន្ធគយ | 376 | 432 | 376 | 376 | 424 | 395 | 513 | 5,73 | 151.7 | 157.2 | 200.0 | - |
| ពនកងរតរក | - | - | - | - | - | - | - | - | - | - | - | 150.3 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | - | - | - | - | 72.2 |
| ចំណូលមិនមែនពន្ធ | 204 | 348 | 424 | 424 | 501 | 513 | 530 | 563 | 168.3 | 151.0 | 183.1 | 35.5 |
| អាជីវកម្មព្រៃឈើ | 20 | 36 | 28 | 29 | 15 | 7 | 2 | 3 | 0.7 | 0.3 | 0.9 | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 88 | 108 | 124 | 122 | 123 | 120 | 94 | 123 | 30.0 | 11.7 | 30.0 | - |
| ក៏ពពពរពើអេពពរទរទេពរ | - | - | - | - | - | - | - | - | - | - | - | 2.9 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | - | - | - | - | 30.3 |
| ចំណូលជាមូលធន | 36 | 12 | 8 | 9 | 16 | 31 | 19 | 152 | 4.6 | 15.4 | 354.7 | 0.0 |
| ចំណាយសរុប | 1348 | 1788 | 2332 | 2332 | 2948 | 2757 | 2932 | 3295 | 1012.0 | 924.0 | 1078.4 | 101.7 |
| ចំណាយជាមូលធន | 368 | 624 | 976 | 977 | 1388 | 1171 | 1163 | 1328 | 386.6 | 317.2 | 349.8 | 76.0 |
| ចំណាយចរន្ត | 980 | 1164 | 1356 | 1355 | 1560 | 1586 | 1769 | 1967 | 625.4 | 606.9 | 728.7 | 25.8 |
| អប់រំ និងសុខាភិបាល | 132 | 280 | 344 | 343 | 454 | 473 | 518 | 351 | 202.3 | 150.1 | 281.3 | - |
| ការពារជាតិ និងសន្តិសុខ | 448 | 464 | 404 | 405 | 438 | 411 | 423 | 451 | 116.7 | 155.3 | 170.1 | - |
| ក្រសួងផ្សេងៗទៀត | 332 | 412 | 636 | 637 | 668 | 702 | 828 | 1165 | 306.4 | 301.5 | 277.3 | - |
| របវតរ | 448 | 518 | 517 | 509 | 587 | 615 | 640 | 711 | 210.3 | 230.6 | 240.6 | 13.7 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | - | - | - | - | - | - | - | - | - | 4.0 |
| ឱនភាពទូទៅ | -428 | -462 | -804 | -802 | -1,204 | -993 | -806 | -706 | -280.5 | -191.9 | 120.7 | 65.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 268 | 416 | 768 | 766 | 1,249 | 886 | 864 | 1127 | 333.3 | 228.6 | 296.5 | 78.8 |
| ហិរញ្ញប្បទានក្នុងស្រុក | 112 | 60 | 36 | 37 | -45 | 106 | 148 | -396 | -52.8 | -36.7 | -417.2 | -261.3 |

*Provisional for 2007. Data available to January 2007.*

### តារាង ៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួល) អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៩-២០០៧

| | 1999 | 2000 | 2001* | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 16.4 | 15.8 | 12.0 | 8.5 | 7.2 | 4.3 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 5.8 | 6.1 | 4.5 | 4.9 | 3.4 | 3.0 |
| - ម្ហូបអាហារ | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 8.6 | 10.6 | 6.3 | 5.8 | 3.3 | 3.0 |
| - ដឹកជញ្ជូន | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 11.4 | 9.7 | 10.0 | 10.1 | 6.8 | 5.2 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4119.7 | 4094.8 | 4106.6 | 4145.3 | 4129.4 | 4063.0 |
| រៀលក្នុង ១ បាតថៃ* | - | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 102.6 | 103.5 | 108.0 | 110.3 | 113.0 | 113.7 |
| រៀលក្នុង ១០០ ដុងវៀតណាម* | - | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.8 | 25.4 | 25.0 | 24.9 | 25.0 | 24.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 54.0 | 64.2 | 72.2 | 73.0 | 72.8 | 77.7 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1,065 | 1105 | 1329 | 1521 | 1508 | 2088 | 2633 | 2867 | 3110 | 3333 | 3250 | 3067 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,613 | 1760 | 2113 | 2084 | 2150 | 2833 | 3442 | 3767 | 4000 | 4200 | 4050 | 3750 |

*Sources: CDRI, IMF, NIS, Ministry of Planning, Ministry of Economy and Finance*

### តារាង ៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៩-២០០៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 2019 | 2589 | 3080 | 3737 | 4027 | 4797 | 5475 | 6410 | 6682 | 6958 | 7224 | 8056 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -576 | -759 | -876 | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 | -263 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 103 | 3 | -75 | -119 | -128 | -209 | -421 | -755 | -831 | -892 | -953 | -1176 |
| ឥណទានចំពោះផ្នែកឯកជន | 763 | 898 | 936 | 1059 | 1337 | 1817 | 2394 | 2778 | 2997 | 3288 | 3628 | 4066 |
| រូបិយវត្ថុទូទៅ M2 | 1443 | 1830 | 2204 | 2888 | 3329 | 4330 | 5025 | 5711 | 6045 | 6461 | 6942 | 7793 |
| រូបិយវត្ថុ M1 | 531 | 540 | 609 | 813 | 937 | 1153 | 1323 | 1449 | 1512 | 1563 | 1658 | 1794 |
| រូបិយវត្ថុផ្សេងៗ | 912 | 1290 | 1595 | 2075 | 2392 | 3177 | 3702 | 4262 | 4533 | 4898 | 5285 | 5999 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 17.3 | 26.8 | 20.4 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 | 36.5 |
| រូបិយវត្ថុ M1 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 | 23.9 |
| រូបិយវត្ថុផ្សេងៗ | 32.7 | 41.4 | 23.6 | 30.0 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 | 40.7 |

*Source: National Bank of Cambodia*

### តារាង ៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 វិច្ឆិកា | 2003 | 2004 | 2005 | 2006 ឧសភា | 2007 សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | 2006 វិច្ឆិកា | 2007 កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 8546 | 6063 | 7393 | 6534 | 9245 | -5 | -17 | 8 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7375 | 5238 | 7045 | 6010 | 9798 | 9 | -8 | 33 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6492 | 5197 | 6125 | 6125 | 11178 | -27 | -1 | 38 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 4512 | 4266 | 3903 | 4530 | 5533 | -19 | -9 | 23 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4243 | 4292 | 4498 | 4078 | 5150 | 16 | -13 | 21 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4541 | 4137 | 4653 | 4126 | 4278 | 10 | 0 | 0 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 7860 | 9264 | 8957 | 11146 | 8347 | 3 | 21 | 6 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8790 | 6744 | 8386 | 9144 | 12886 | -13 | 3 | 47 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6407 | 6028 | 5263 | 5094 | 6075 | -21 | -15 | -5 |
| កម្មករសំណង់មានជំនាញ | 13127 | 13111 | 12679 | 10316 | 9833 | 9466 | 10215 | 10146 | 11892 | -9 | -14 | 21 |

** Waitresses' earnings do not include meals and accommodation provided by shop owners.*
*Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motocycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗពី...**

## ផ្នែកស្រាវជ្រាវ

នៅថ្ងៃទី២០-២១ សីហា ២០០៧ បណ្តាញវិភាគអភិវឌ្ឍន៍ បានជួបប្រជុំនៅទីក្រុងភ្នំពេញ ដើម្បីពិភាក្សាអំពីវិធីសាស្ត្រចុះស្រាវជ្រាវតាមដានខ្សែរយៈទីផ្សារនៃដំណាំកៅស៊ូ ដំឡូងមី និងបសុសត្វ ។ នៅថ្ងៃទី២៩ សីហា ផ្នែកអភិបាលកិច្ច បានបើកសិក្ខាសាលាបំផុសគំនិត ដើម្បីដាក់ដំណើរការកម្មវិធីស្រាវជ្រាវស្តីពីអភិបាលកិច្ច និងកំណែទំរង់សាធារណៈ ។ នៅថ្ងៃបន្ទាប់ទី៣០ សីហា ២០០៧ CDRI បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ស្តីពីដំណោះស្រាយរបស់មនុស្សពេលជួបគ្រោះធម្មជាតិដែលជាការងារស្ថិតក្នុងគំរោងវិភាគបញ្ហាអភិវឌ្ឍន៍របស់ CCC (ADI/CCC) ។ នៅថ្ងៃទី១២-១៣ កញ្ញា CDRI បានសហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) រៀបចំវេទិកាជួបជុំដៃគូទាំងអស់របស់ IDRC ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការកំណត់គោលដៅផ្តល់ជំនួយស្រាវជ្រាវរបស់ IDRC ដល់កម្ពុជា ។

ទាក់ទិននឹងគំរោងស្រាវជ្រាវ ការសិក្សាអំពីការចាកផុតពីភាពក្រីក្រ បានចប់រួចរាល់ និងបានបោះពុម្ពផ្សាយរបាយការណ៍នៅខែកញ្ញា ។ គំរោងថ្មីមួយទៀតស្តីពី ពាណិជ្ជកម្ម និងបរិស្ថាន បានចាប់ដំណើរការ នៅខែកញ្ញាដោយទទួលបានមូលនិធិពីបណ្តាញចំណេះដឹងពាណិជ្ជកម្ម ដែលមានទីចាត់ការធំនៅក្រុងហ្សឺណែវ ។